**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អធិដ្ឋានពេញមួយយប់នៅផ្សារតូច**
**ថ្ងៃទី០៧ ធ្នូ ២០១៧**
*ក្រុមគ្រួសារជាកន្លែងមួយដើម្បីឲ្យការត្រាស់ហៅកើតឡើង*

អត្ថបទទី១៖ អស ២៦,១-៦
ដំណឹងល្អ៖ មថ ៧,២១.២៤-២៧

បងប្អូនជាទីស្រឡាញ់!

យប់នេះយើងមកពីមណ្ឌលសកម្មភាពទាំងបី នៅក្នុងរាជធានីភ្នំពេញ ដើម្បីកោតសរសើរព្រះនាងម៉ារីនិងកោតសរសរព្រះជាម្ចាស់ ដែលបានប្រទេសព្រះនាងម៉ារីសម្រាប់ព្រះសហគមន៍ ជាពិសេសនៅក្នុងរដូវរង់ចាំ នៅពេលយើងសម្លឹងមើលព្រះនាងម៉ារី យើងទៅរករបៀបសម្រាប់ជីវិតរបស់យើងផ្ទាល់។ មុនគេបង្អស់ព្រះជាម្ចាស់តាមរយៈទេវទូតកាព្រីអែល គឺជាព្រះជាម្ចាស់ផ្ទាល់ដែលបានយាងមកដើម្បីសួរសុខទុក្ខព្រះនាងម៉ារី ដើម្បីជួបជាមួយព្រះនាងម៉ារី។ នៅក្នុងរដូវរង់ចាំនេះ ឲ្យយើងយកចិត្តទុកដាក់ដើម្បីព្រះជាម្ចាស់យាងមកសួរសុខទុក្ខយើងផ្ទាល់។ មិនមែនឲ្យយើងរៀបចំខ្លួនដើម្បីទីថ្វាយបង្គំព្រះយេស៊ូនីយប់បុណ្យណូអែល ប៉ុន្តែជាយើងចាប់ពីពេលនេះតទៅឲ្យយើងបើកចិត្តគំនិត ដើម្បីទុកកន្លែងមួយឲ្យព្រះជាម្ចាស់យាងចូលសួរសុខទុក្ខយើង។ បើយើងបិតទាំងត្រចៀក ទាំងភ្នែក ទាំងបេះដូង ព្រះជាម្ចាស់ឥតមានកន្លែងចូល។ រដូវរង់ចាំនេះជាឱកាសមួយដើម្បីទទួលស្វាគមន៍ព្រះជាម្ចាស់ ដែលយាងមកសួរសុខទុក្ខយើង។

យប់នេះមានប្រធានបទមួយគឺ "**ក្រុមគ្រួសារជាកន្លែងមួយដើម្បីឲ្យការត្រាស់ហៅកើតឡើង**" ក្រុមគ្រួសារគឺជាមូលដ្ឋានគ្រឹះនៃការត្រាស់ហៅ។ យប់នេះយើងសម្លឹងមើលព្រះនាងម៉ារី ព្រះនាងម៉ារីជាកូនម្នាក់ដែលបាននៅជាមួយឪពុកម្តាយ នៅពេលគាត់មានអាយុ៣ឆ្នាំ ឪពុកម្តាយរបស់ព្រះនាងម៉ារីបានទៅទីក្រុងយេរ៉ូសាឡឹមដើម្បីថ្វាយកូនរបស់គេទៅព្រះជាម្ចាស់ តាមប្រពៃណីគេទុកកូនដែលមានអាយុ៣ឆ្នាំនៅក្នុងវិសាលវិហាររហូតដល់អាយុ១១ឆ្នាំ។ ដូច្នេះព្រះនាងម៉ារី បាននៅក្នុងវិសាលវិហារក្រុងយេរ៉ូសាឡឹម៨ឆ្នាំ ដើម្បីរៀបចំខ្លួន ដើម្បីស្គាល់ព្រះជាម្ចាស់ ដើម្បីស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីចេះអធិដ្ឋាន ដើម្បីចេះស្មូត ដើម្បីជិតស្និទ្ធជាមួយព្រះជាម្ចាស់។ ដូច្នេះមុនគេបង្អស់គឺឪពុកម្តាយរបស់ព្រះនាងម៉ារី ដែលបានយកចិត្តទុកដាក់ដើម្បីឲ្យកូនគេជិតស្និតជាមួយព្រះជាម្ចាស់។ នៅពេលព្រះនាងម៉ារីទទួលដំណឹងល្អពីទេវទូតកាព្រីអែល ព្រះនាងម៉ារីបានរៀបចំខ្លួនអស់ហើយ ដោយសារឪពុកម្តាយរបស់គាត់ដែលបានយកចិត្តទុកដាក់ ដើម្បីឲ្យកូនស្គាល់ព្រះជាម្ចាស់ ស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីឲ្យកូនមាននិស្ស័យពិសេសជាមួយព្រះជាម្ចាស់។ នៅពេលទេវទូតកាព្រីអែល យាងមកសួរសុខទុក្ខព្រះនាងម៉ារី ទោះបីឆ្ងល់ ទោះបីរំភើប ទោះបីភ័យ

ប៉ុន្តែព្រះនាងម៉ារីបានទទួល ដោយសារចិត្តគំនិតរបស់គាត់បានត្រៀមជាស្រេច។ សម្រាប់ឪពុកម្តាយ ឲ្យយើងយល់ថា យើងជាឪពុកម្តាយតួនាទីទីមួយគឺធ្វើដូចម្តេចដើម្បីណែនាំឲ្យកូនយើងស្គាល់ព្រះជាម្ចាស់ ស្រឡាញ់ព្រះជាម្ចាស់ បង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់ ដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់។

នៅផ្សារតូចនេះ យើងមានធាតុរបស់ឪពុកម្តាយសន្តីតេរេសា ប៉ុន្មានឆ្នាំមុនព្រះសហាគមន៍បានតែងតាំងអ្នកទាំងពីរជាសន្តសន្តី ដើម្បីទៅជាឪពុកម្តាយគំរូសម្រាប់យើងទាំងអស់។ ឪពុករបស់សន្តីតេរេសាបាននិយាយថា "ខ្ញុំចិញ្ចឹមកូនរបស់ខ្ញុំ ដើម្បីរៀបចំកូនរបស់ខ្ញុំមានកន្លែងមួយនៅស្ថានបរមសុខ" នេះជាគោលដៅរបស់គាត់។ អស់មួយជីវិតរបស់គាត់បានយកចិត្តទុកដាក់ អប់រំ ចិញ្ចឹម ណែនាំ កូនរបស់គាត់ ដើម្បីឲ្យកូនរបស់គាត់មានកន្លែងមួយយ៉ាងពិសេសនៅស្ថានបរមសុខ។ សម្រាប់យើងជាឪពុកម្តាយក៏ដូចគ្នាដែល រាល់ពេលយប់គេអធិដ្ឋានជាមួយកូនរបស់គេ រាល់ថ្ងៃអាទិត្យគេចូលព្រះវិហារជាមួយក្រុមគ្រួសាររបស់គេ។ នេះជារបៀប ដើម្បីឲ្យបន្តិចម្តងៗកូនរបស់យើង ស្គាល់ព្រះជាម្ចាស់ ស្គាល់ព្រះយេស៊ូ ស្គាល់ព្រះនាងម៉ារី និងរៀបចំខ្លួនដូចព្រះនាងម៉ារីដើម្បីទទួលស្វាគមន៍ព្រះយេស៊ូដែលជាព្រះជាម្ចាស់ផ្ទាល់។

យើងសម្លឹងមើលក្រុមគ្រួសារព្រះនាងម៉ារីថែមទៀត នៅពេលគាត់បានធ្វើដំណើរពីភូមិណាសារ៉ែតទៅភូមិបេថ្លេហិម ដើម្បីធ្វើជំរឿនប្រជាជន នៅពេលនោះយើងបានឃើញរបៀបដែលលោកយ៉ូសែបបានយកចិត្តទុកដាក់ជាមួយក្រុមគ្រួសាររបស់គាត់ ឥតមានកន្លែងស្នាក់នៅ ឥតមានកន្លែងដើម្បីឆ្លងទន្លេ ប៉ុន្តែគាត់បានរកកន្លែងមួយដែលមានសត្វផ្សេងៗ ឥតមានខ្យល់ ដើម្បីឲ្យព្រះនាងម៉ារីឆ្លងទន្លេបាន។ នៅពេលព្រះយេស៊ូបានប្រសូតហើយ ប៉ុន្មានថ្ងៃក្រោយមកគេត្រូវការគេចខ្លួនទៅប្រទេសអេហ្ស៊ីប ដោយសារស្តេចហេរ៉ូដចង់សម្លាញ់កូនក្មេងទាំងអស់។ នៅពេលនោះលោកយ៉ូសែប និងព្រះនាងម៉ារីបានទទួលខុសត្រូវយ៉ាងខ្ពស់ដោយសារឆ្លងព្រំដែនមិនស្រួលទេ ប៉ុន្តែគេបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងសុបិន្តដែលថា សូមទៅប្រទេសអេហ្ស៊ីបសិនពេលស្ងាត់ចាំត្រលប់មកវិញ។ គេមិនតែស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប៉ុន្តែគេបានអនុវត្តផ្ទាល់ដោយទទួលខុសត្រូវយ៉ាងខ្ពស់ ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ដឹកនាំជីវិតរបស់គេជាមួយក្រុមគ្រួសាររបស់គេ។ របៀបដែលព្រះនាងម៉ារីនិងលោកយ៉ូសែប បានយកចិត្តទុកដាក់ជាមួយកុមារយេស៊ូ ជាពិសេសដល់ពេលវេលាឲ្យកុមារយេស៊ូថ្វាយខ្លួននៅវិហារយេរ៉ូសាឡឹម។ នៅពេលកុមារយេស៊ូអាយុ ១២ឆ្នាំ លោកយ៉ូសែបនិងព្រះនាងម៉ារីនៅជាមួយព្រះកុមារយេស៊ូ មានមហាជនច្រើននៅទីក្រុងយេរ៉ូសាឡឹមថ្ងៃនេះ ពេលត្រលប់ទៅវិញលោកយ៉ូសែបនិងព្រះនាងម៉ារីគិតថាព្រះកុមារយេស៊ូ កំពុងលេងជាមួយក្មេងៗផ្សេង ប៉ុន្តែបាត់ព្រះយេស៊ូបីថ្ងៃ ព្រះនាងម៉ារីជាមួយលោកយ៉ូសែបបានខិតខំដើរ

រក ដោយមិនស្មានថាកូនរបស់គេកំពុងអប់រំគ្រីស្តបរិស័ទនៅព្រះវិហារយេរ៉ូសាឡឹមទេ។ នៅពេលព្រះនាងម៉ារីបានឃើញកូន គាត់សប្បាយចិត្តហើយមិនបានស្តីឲ្យកូនសោះ។ ព្រះនាងម៉ារីនិងលោកយ៉ូសែប បានយកចិត្តទុកដាក់អប់រំណែនាំ ដើម្បីឲ្យកូនគេរីកចម្រើនតាមព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់។

ថ្ងៃនេះឲ្យយើងចាប់អារម្មណ៍អំពី ការយកចិត្តទុកដាក់រវាងប្តីនិងប្រពន្ធ (ម៉ារីនិងយ៉ូសែបដើម្បីឆ្លងទន្លេ) ការទទួលខុសត្រូវយ៉ាងខ្ពស់ដោយស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងការអប់រំណែនាំ ស្រឡាញ់ យកចិត្តទុកដាក់ជាមួយកូន ដូចព្រះនាងម៉ារីនិងលោកយ៉ូសែប ដែលបានថែរក្សាស្រឡាញ់ និងអប់រំព្រះយេស៊ូ ដើម្បីឲ្យព្រះយេស៊ូចូលតាមព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ជានិច្ច។

ដូច្នេះយើងមានគំរូគ្រួសារមួយយ៉ាងពិសេស សម្រាប់ក្រុមគ្រួសារទាំងអស់ ដើម្បីឲ្យព្រះសហគមន៍របស់យើងបន្តិចម្តងៗចាក់ឫសតាមរយៈគ្រួសារនីមួយៗ ដើម្បីឲ្យព្រះសហគមន៍របស់យើងមានសមត្ថភាពណែនាំកូនប្រុសស្រីចូលបម្រើព្រះសហគមន៍របស់យើងអស់មួយជីវិត។ ថ្ងៃនេះយើងអធិដ្ឋានតាមរយៈព្រះនាងម៉ារីនិងសន្តយ៉ូសែប យើងអធិដ្ឋានតាមរយៈឪពុកម្តាយសន្តីតេរេសា ដើម្បីឲ្យយើងទាំងអស់គ្នាមានកម្លាំងអប់រំ ស្រឡាញ់ បម្រើ ឲ្យកូនរបស់យើងស្គាល់ព្រះជាម្ចាស់យ៉ាងជិតស្និទ្ធ និងធ្វើដូចម្តេចដើម្បីណែនាំកូនរបស់យើងឆ្លងតបនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់ នេះជាតួនាទីរបស់ឪពុកម្តាយដើម្បីណែនាំឲ្យព្រះសហគមន៍របស់យើងមានជីវិតថែមទៀត។ សូមអរព្រះគុណព្រះជាម្ចាស់ ដែលបានប្រទានព្រះនាងម៉ារី និងបានណែនាំឲ្យយើងមានគំរូមួយយ៉ាងពិសេស ព្រះនាងម៉ារីជាស្ត្រីសាមញ្ញបំផុត ប៉ុន្តែជាស្ត្រីដែលមានជីវិតអស្ចារ្យបំផុត។ អាម៉ែន៕